ជំពូកទី១ # សង្គ្រាមលោក និង អង្គការរក្សាសន្តិភាព

មេរៀនទី១ ## សង្គ្រាមលោកលើកទី១ (1914-1918)

សង្គ្រាមលោកជាសង្គ្រាមដែលមានការចូលរួមពីសំណាក់ប្រទេសជាច្រើន ហើយរីករាលដាលពាសពេញពិភពលោក។

សង្គ្រាមលោកលើកទី ១ ផ្ទុះឡើងនៅក្នុងទ្វីបអ៊ឺរ៉ុប ចាប់ពីឆ្នាំ 1914-1918 បណ្តាលមកពីមូលហេតុពីរយ៉ាងគឺ:

- ពួកមហាអំនាចថ្មី ដណ្តើមទីផ្សារ របស់ពួមហាអំនាចចាស់
- ការធ្វើឃាតទៅលើស្តេចឈ្មោះ **ហ្វ្រង់ស័រហ្វ៊ែឌីណង់** ដែលជារាជទាយាទរបស់ អូទ្រីស ហុងគ្រី ដោយនិស្សិត ស៊ែប៊ី។

សង្គ្រាមលោកលើកទី ១ មានកម្លាំងពីរប្រឈមគ្នា:

- **ប្លុកទី១ សម្ព័ន្ធត្រីភាគី**: មានអាឡឺម៉ង់ អូទ្រីស ហុងគ្រី ក្រោយមកទៀត មាន តួគី និង ប៊ុលការី
- **ប្លុកទី២ អនុសញ្ញាត្រីភាគី**: មាន បារាំង អង់គ្លេស រុស្ស៊ី ក្រោយមកទៀត មាន ប៊ែលហ្សិក ស៊ែប៊ី អ៊ីតាលី ជប៉ុន ក្រិច រ៉ូម៉ានី និងសហរដ្ឋអាមេរិច។

គេចែកចម្បាំងនៅក្នុងសង្គ្រាមលោកលើកទី១ ជាបីដំណាក់កាលសំខាន់ៗ ដែលក្នុងដំនាក់កាលនិមួយៗ មានការប្រយុទ្ធគ្នាយ៉ាងសាហាវព្រៃផ្សៃ ហើយភាគីទាំងសងខាងប្រើប្រាស់មធ្យោបាយថ្មី ដូចជា កាំភ្លើងធំ យន្តហោះ ផ្សែងឈ្លក់ រថក្រោះ នាវា មុជទឹក ...។ ទីបញ្ចប់ភាគីអាឡឺម៉ង់ បានចាញ់ទាំងស្រុង ហើយសង្គ្រាមលោកលើកទីមួយត្រូវបានបញ្ចប់។

ក្រោយពីអាឡឺម៉ង់ចាញ់សង្គ្រាម គេបានបង្កើតសន្ធិសញ្ញាបញ្ចប់សង្គ្រាមចំនួនពីរគឺ:

- **សន្ធិសញ្ញាក្រុងប៉ារីស**: ចាប់ផ្តើមពីខែ មករា ដល់ មិថុនា ឆ្នាំ 1919 ដោយមានប្រទេស 32 ចូលរួម ហើយសេចក្តីផ្សេងៗសំរេចដោយចតុភាគីមាន អាមេរិច បារាំង អ៊ីតាលី និង អង់គ្លេស  ដោយផ្តោតទៅលើ ការបែងចែកដែនដីទ្វីបអ៊ឺរ៉ុប និងការបង្កើតសង្គមប្រជាជាតិដើម្បីរក្សាសន្តិភាព។
- **សន្ធិសញ្ញាវែរសៃ**: មានការចូលរួមចំនួន 27 ប្រទេស និង ចុះហត្ថលេខាដោយ អាឡឺម៉ង់ នៅថ្ងៃទី 28 មិថុនា 1919 ។ សន្ធិសញ្ញានេះតម្រូវអោយអាឡឺម៉ង់ ប្រគល់ទឹកដី អាល់សាល និង ឡរ៉ែន អោយទៅ បារាំង ប្រគល់រដ្ឋ ប៉ូស្នាន អោយទៅ ប៉ូឡូញ និង លះបង់ទឹកដីនៃ អាណានិគម ទាំងអស់ ហើយត្រូវចំណាយ 33 ពាន់លានដុល្លា សំរាប់ជូសជុលការខូចខាត។

សង្គ្រាមលើកទី 1 បានបំផ្លាញជីវិតមនុស្សអោយស្លាប់ក្នុងសង្គ្រាមប្រហែល 10 លាននាក់ និង រងរបួសប្រហែល  20លាននាក់ ធ្វើអោយខូចខាតសម្ភារៈជាច្រើនដូចជា ផ្ទះសំបែង រោងចក្រ ផ្លូវគមនាគមន៍ សាលារៀន និង បន្សល់ទុកនៅ ជនពិកា ក្មេងកំព្រា ស្ត្រីមេម៉ាយដោយរស់រងទុក្ខវេទនាពាសពេញពិភពលោក។

ក្រោយពេលសង្គ្រាមលោកលើកទី១ បានបញ្ចប់ លោក វិល សុន ប្រធានាធិបតី អាមេរិចបានចាប់ផ្តើមគំនិតបង្កើតសង្គមប្រជាជាតិមួយដើម្បីចៀសវាងចម្បាំងជាថ្មីម្តងទៀត។ សង្គមប្រជាជាតិត្រូវបានបង្កើតនៅថ្ងៃទី 29 ខែ មេសា 1919 ដែលមានទីស្នាក់ការ នៅទីក្រុង ស៊្វីណែវ។

សង្គមប្រជាជាតិមានអង្គការជាច្រើនទៀតដូចជា: មាហាសន្និបាត ក្រុងអភិបាលការិយាល័យអចិន្ត្រៃយ៍ ការិយាល័យអន្តរជាតិ និង តុលាកាអន្តរជាតិ។ សង្គមប្រជាជាតិមិនអាចរារាំងចម្បាំងបានឡើយ នៅឆ្នាំ 1939 អាឡឺម៉ង់បង្កសង្គ្រាមលោកលើទី ២ ម្តងទៀត។

បង្រៀនដោយ លោកគ្រូ អ៊ូ សៅ
មុខវិជ្ជា ប្រវត្តិវិទ្យា ថ្នាក់ទី៩
សូមសំណាងល្អពេលប្រលង